**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខៈ ២៨.៦៧...PC.អក

# សេចក្តីជូនដំណឹងលើកទី២
## ស្តីពី
## ការផ្គត់ផ្គង់ម៉ាស៊ីនរាប់លុយ = 05 គ្រឿង, ម៉ាស៊ីនពិនិត្យលុយក្លែងក្លាយ = 01 គ្រឿង និង ម៉ាស៊ីនបូកលេខព្រីន = 05 គ្រឿង ជូនសាខាអូរដឹម នៃនាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាៈអគ្គិសនីកម្ពុជានឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលចូលរួមពិគ្រោះថ្លៃស្តីពី **ការផ្គត់ផ្គង់ម៉ាស៊ីនរាប់លុយ = 05 គ្រឿង, ម៉ាស៊ីនពិនិត្យលុយក្លែងក្លាយ =01 គ្រឿង និងម៉ាស៊ីនបូកលេខព្រីន = 05 គ្រឿង ជូនសាខាអូរដឹម នៃនាយកដ្ឋានអាជីវកម្មចែកចាយ។**

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋានៈ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២១ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងៈ 023 67 66 007 និង Website: www.edc.com.kh )។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ១១ : 00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ១៥:00 នាទី ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃពុធ ២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០២១
**ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហង់_ទូច**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ